ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# អាជ្ញាធរទន្លេសាប

# ផែនការសកម្មភាពការងារប្រចាំឆ្នាំ ២០១៦
# អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប

រៀបចំដោយ ៖ អាជ្ញាធរទន្លេសាប

សម្របសម្រួលក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប

ខែមករា ឆ្នាំ ២០១៦

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរទន្លេសាប

លេខ : ០០៤/១៦ អទស

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែ មករា ឆ្នាំ២០១៦

**ជម្រាបមក**
**ឯកឧត្តម លោកប្រធាន និងអនុប្រធានក្លាប់រួមនាយកដ្ឋាន**
**ក្រោមឱវាទអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប**

**កម្មវត្ថុ ៖** ការដាក់ឲ្យអនុវត្តន៍ផែនការសកម្មភាពការងារប្រចាំឆ្នាំ 2016 របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ។

**ជូនភ្ជាប់ ៖** ផែនការសកម្មភាពការងារប្រចាំឆ្នាំ 2016 របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងជូនភ្ជាប់ខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តម លោកប្រធាន និងអនុប្រធានក្លាប់រួម ជ្រាបថា ៖ ក្នុងស្មារតីយកចិត្តទុកដាក់ជម្រុញនូវកិច្ចការការពារធនធានធម្មជាតិ និងជីវៈចម្រុះ ដែលជាផ្នែកមួយយ៉ាងសំខាន់ក្នុងការលើកកម្ពស់សេដ្ឋកិច្ចជាតិ និងការទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ ប្រកបដោយចីរភាព ។

អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប បានរៀបចំផែនការសកម្មភាពការងារប្រចាំឆ្នាំ 2016 ដើម្បីជម្រុញប្រសិទ្ធភាពការអនុវត្តផែនការយុទ្ធសាស្ត្រ អាជ្ញាធរទន្លេសាប 2016-2020 ឲ្យទទួលបានជោគជ័យ និងបន្តពង្រឹងការអនុវត្តបេសកកម្មស្នូលរបស់អាជ្ញាធរទន្លេសាប ក្នុងការសិក្សាស្រាវជ្រាវ តាមដានត្រួតពិនិត្យ និងវាយតម្លៃ អំពីសក្តានុពលសេដ្ឋកិច្ច សង្គមកិច្ច និងធនធានធម្មជាតិ ស្របតាមអាណត្តិការងារសម្របសម្រួលដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប ប្រកបដោយនិរន្តរភាព ។

អាស្រ័យហេតុនេះ សូមឯកឧត្តម លោកប្រធាន និងអនុប្រធានក្លាប់រួមនាយកដ្ឋាន ក្រោមឱវាទអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប អនុវត្តន៍ឲ្យបានល្អប្រសើរ និងមានប្រសិទ្ធភាព ។

**រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម**
**និងជា ប្រធានអាជ្ញាធរទន្លេសាប**

**លឹម គានហោ**

អគារលេខ: ៣៦៤,មហាវិថី ព្រះមុនីវង្ស,សង្កាត់ ផ្សារដើមថ្កូវ,ខណ្ឌ ចំការមន,រាជធានីភ្នំពេញ, ទូរស័ព្ទ / ទូរសារលេខ: (៨៥៥) ២៣ ៧២៧ ៤៥៤
# 364 Monivong Blvd., Phsar Deumthkov, Khan Chamkarmorn, Phnom Penh, Cambodia. Phone/Fax: (855) 23 727 454, Website: www. tonlesap.gov.kh

# អារម្ភកថា

បឹងទន្លេសាប គឺជាបឹងទឹកសាបធំជាងគេបំផុតក្នុងភូមិភាគអាស៊ីអាគ្នេយ៍ និងជាបេះដូងនៃប្រទេសកម្ពុជា មានតម្លៃមិនអាចកាត់ថ្លៃបាន ។ ទន្លេសាប និងបឹងទន្លេសាប គឺជាប្រព័ន្ធផ្លូវទឹកទំនាក់ទំនងយ៉ាងសំខាន់បំផុត ដែលទទួលរងនូវឥទ្ធិពលរបបទឹកពីទន្លេមេគង្គ ។ បឹងទន្លេសាប ស្រូបយកទឹកពីទន្លេមេគង្គនៅរដូវវស្សា និងបញ្ចេញទឹកទៅទន្លេមេគង្គវិញនៅរដូវប្រាំង បង្កើតបានជាបាតុភូតជលសាស្ត្រធម្មជាតិមួយកម្រមាននៅលើពិភពលោក និងបាននាំមកនូវដីល្បាប់ដ៏មានជីជាតិ ចាក់បំពេញវាលទំនាបលិចទឹកនៃតំបន់ព្រៃលិចទឹកដ៏ធំល្វឹងល្វើយ ដែលជាជម្រក និងបង្កបានជាចំណី សម្រាប់ជីវៈចម្រុះយ៉ាងសម្បូរបែប មានពពួកមច្ឆាជាតិ បក្សី ល្មូន ថនិកសត្វ និងរុក្ខជាតិគ្រប់ប្រភេទ ។ ក្រៅពីតួនាទីជាបឹង ទទួលយកទឹក និងជួយកាត់បន្ថយគ្រោះទឹកជំនន់ពីទន្លេមេគង្គ វាក៏ជាប្រភពសន្តិសុខស្បៀង ជួយទ្រទ្រង់ដល់ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា និងជួយទ្រទ្រង់ដល់វិស័យសេដ្ឋកិច្ច សង្គម វប្បធ៌ម និងបរិស្ថានប្រទេសជាតិទាំងមូល ។

បច្ចុប្បន្នសម្ពាធនៃការអភិវឌ្ឍ និងកំណើនប្រជាពលរដ្ឋ បានធ្វើឲ្យហានិភ័យនៃបឹងទន្លេសាប បាននឹងកំពុងទទួលរងនូវការគម្រាមកំហែងយ៉ាងធ្ងន់ធ្ងរ មកដល់សុខមាលភាពបឹង បរិស្ថាន ជីវៈចម្រុះ និងធនធានធម្មជាតិ ដូចជា ៖ ការប្រើប្រាស់បច្ចេកវិជ្ជាខុសបទដ្ឋានបច្ចេកទេស ការកាប់បំផ្លាញ រុករានទន្ទ្រានយកដីព្រៃលិចទឹក ការធ្វើអាជីវកម្មហួសកម្រិតលើធនធានជលផល បម្រែបម្រួលអាកាសធាតុ ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងការសាងសង់ទំនប់វារីអគ្គិសនីនៅផ្នែកខាងលើ ជាដើម ។

ដោយមើលឃើញពីសារៈសំខាន់នៃបឹងទន្លេសាប និងដើម្បីចូលរួមចំណែកក្នុងកិច្ចការការពារធនធានធម្មជាតិ និងជីវៈចម្រុះ ដែលជាផ្នែកមួយយ៉ាងសំខាន់ក្នុងការលើកកម្ពស់សេដ្ឋកិច្ចជាតិ និងការទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ជាពិសេសការធានាដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ធនធានដ៏កម្រនៅតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធប្រកបដោយនិរន្តរភាព ក៏ដូចជាការចូលរួមពង្រឹងប្រសិទ្ធភាពគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា **អាជ្ញាធរទន្លេសាប** បានរៀបចំផែនការសកម្មភាពការងារប្រចាំឆ្នាំ 2016 ដែលជាផែនការសកម្មភាពនៃឆ្នាំទី 3 របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប បន្តពីការអនុវត្តផែនការសកម្មភាពការងារប្រចាំឆ្នាំ 2015 ។

ផែនការសកម្មភាពការងារប្រចាំឆ្នាំ 2016 គឺជាសកម្មភាពការងារលម្អិត ក្នុងការប្រតិបត្តិអនុវត្តន៍ការងារប្រចាំឆ្នាំរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប រួមជាមួយការចូលរួមសហការពីបណ្តាក្រសួង ស្ថាប័នទាំងកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សង្គមស៊ីវិល អង្គការជាតិ-អន្តជាតិ និងដៃគូអភិវឌ្ឍន៍នានា ដើម្បីជម្រុញ ប្រសិទ្ធភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រ អាជ្ញាធរទន្លេសាប 2016-2020 ឲ្យទទួលបានជោគជ័យ ។ ជាមួយខ្លឹមសារផែនការសកម្មភាពការងារនេះ ក៏ត្រូវបានរៀបចំបន្ស៊ីជាមួយគម្រោងសកម្មភាពការងារអាទិភាពសំខាន់ៗនៅក្នុងផែនការយុទ្ធសាស្ត្រ អាជ្ញាធរទន្លេសាប 2016-2020 ។ ជាពិសេស ស្របតាមតួនាទី ភារកិច្ចការងារ ដែលបានកំណត់ក្នុងអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ដើម្បីពង្រឹងប្រសិទ្ធភាពការងារ និងគាំទ្រដល់បេសកកម្ម

ការងាររបស់អាជ្ញាធរទន្លេសាបក្នុងការសម្របសម្រួលដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប ប្រកបដោយនិរន្តរភាព ។

ផែនការសកម្មភាពការងារនេះ ចែកជា 5 ផ្នែកសំខាន់ៗគឺ ៖ ផ្នែកទី 1 រចនាសម្ព័ន្ធ និងតួនាទីភារកិច្ចរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ។ ផ្នែកទី 2 វឌ្ឍនភាពអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ 2015 បង្ហាញពីលទ្ធផលសម្រេចបាន និងបទពិសោធន៍នៃការអនុវត្តសកម្មភាពការងារនៅក្នុងឆ្នាំ 2015 ។ ផ្នែកទី 3 គម្រោងសកម្មភាពការងារអាទិភាពសំខាន់ៗ នៃផែនការយុទ្ធសាស្ត្រ អាជ្ញាធរទន្លេសាប 2016-2020 បង្ហាញពីគម្រោងសកម្មភាពការងារលម្អិត ដើម្បីគាំទ្រការអនុវត្តផែនការយុទ្ធសាស្ត្ររយៈពេល 5 ឆ្នាំ ។ ផ្នែកទី 4 ផែនការសកម្មភាពការងារប្រចាំឆ្នាំ 2016 របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ដែលជាសកម្មភាពការងារលម្អិតប្រចាំឆ្នាំ ។ និងផ្នែកទី 5 ឧបសម្ព័ន្ធ ។

ជាក់ស្តែង ផែនការសកម្មភាពការងារប្រចាំឆ្នាំ 2016 នេះ នឹងប្រើប្រាស់ធ្វើជាឧបករណ៍ជួយតម្រង់ទិសការងារដល់នាយកដ្ឋាន និងការិយាល័យស្ថិតក្រោមឱវាទអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប សម្រាប់យកទៅអនុវត្តអោយមានប្រសិទ្ធភាព ហើយក៏ជាទស្សនទានដ៏សំខាន់មួយ សម្រាប់ផ្តល់ជូនដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការគិតគូរពិចារណាធ្វើការវិភាជន៍ថវិកាប្រចាំឆ្នាំ និងដៃគូអភិវឌ្ឍន៍នានា ដែលមានគោលបំណងចូលរួមសហការ និងគាំទ្រទាំងផ្នែកថវិកា និងបច្ចេកទេស ដល់ដំណើរការការងាររបស់អាជ្ញាធរទន្លេសាប ។

# មាតិកា


**ផ្នែកទី ១ ៖** រចនាសម្ព័ន្ធ និងតួនាទីភារកិច្ចរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ................................ ១

១. លក្ខណៈទូទៅ ................................................................................................................ ១

២. រចនាសម្ព័ន្ធ និងការគ្រប់គ្រង ................................................................................................ ២

**ផ្នែកទី ២ ៖** វឌ្ឍនភាពអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ 2015 ................................................................... ៣

១. សេចក្តីផ្តើម ................................................................................................................ ៣

២. វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពឆ្នាំ 2015 ........................................................................ ៣

២.១. លទ្ធផលសម្រេចបានសំខាន់ៗ ............................................................................................ ៣

២.២ មេរៀន និងបទពិសោធន៍នៃការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ 2015 ................................................ ៤

**ផ្នែកទី ៣ ៖** គម្រោងសកម្មភាពការងារអាទិភាពសំខាន់ៗ ផែនការយុទ្ធសាស្ត្រអាជ្ញាធរទន្លេសាប (2016-2020) ... ៦

១. លក្ខណៈទូទៅ ................................................................................................................ ៦

២. គម្រោងសកម្មភាពការងារអាទិភាពសំខាន់ៗ .................................................................................. ៦

៣. តារាងម៉ាទ្រីសផែនការសកម្មភាពការងារ (2016-2020) ...................................................................... ១២

**ផ្នែកទី ៤ ៖** ផែនការសកម្មភាពប្រចាំឆ្នាំ 2016 របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ...................... ២០

១. លក្ខណៈទូទៅ ................................................................................................................ ២០

២. សកម្មភាពការងារប្រចាំឆ្នាំ 2016 របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ...................................... ២០

៣. តារាងម៉ាទ្រីសផែនការសកម្មភាពការងារប្រតិបត្តិប្រចាំឆ្នាំ 2016 ........................................................... ៣១

**ផ្នែកទី ៥ ៖** ឧបសម្ព័ន្ធ .................................................................................................... ៤៧

ឧបសម្ព័ន្ធ ១ អង្គការលេខរបស់អាជ្ញាធរទន្លេសាប .............................................................................. ៤៧

ឧបសម្ព័ន្ធ ២ ព្រះរាជក្រឹត្យ ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប ................................................................. ៤៨

ឧបសម្ព័ន្ធ ៣ ព្រះរាជក្រឹត្យ ស្តីពីការកែសម្រួលមាត្រាមួយចំនួនក្នុងការបង្កើតអាជ្ញាធរទន្លេសាប...................... ៥៥

ឧបសម្ព័ន្ធ ៤ អនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន អាជ្ញាធរទន្លេសាប ............ ៦០

ឧបសម្ព័ន្ធ ៥ ប្រកាស ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យ ................................................ ៦៥

# ផ្នែកទី ១
# រចនាសម្ព័ន្ធ និងតួនាទីភារកិច្ចរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប

## ១. លក្ខណៈទូទៅ

អាជ្ញាធរទន្លេសាប គឺជាស្ថាប័នថ្មីមួយ និងជាសេនាធិការបន្ថែមជួយដល់រាជរដ្ឋាភិបាល ក្នុងបេសកកម្មការងារ "**សម្របសម្រួលដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប**" ដែលបានកំណត់នៅក្នុងព្រះរាជក្រឹត្យលេខ នស/រកត/0609/705 ចុះថ្ងៃទី 29 ខែមិថុនា ឆ្នាំ 2009 និងព្រះរាជក្រឹត្យលេខ នស/រកត/0310/258 ចុះថ្ងៃទី 24 ខែមីនា ឆ្នាំ 2010 ស្តីពីការកែសម្រួលមាត្រា 3 មាត្រា 5 មាត្រា6 មាត្រា 9 មាត្រា 10 និងមាត្រា 12 នៃព្រះរាជក្រឹត្យលេខ នស/រកត/0609/705 ចុះថ្ងៃទី 29 ខែមិថុនា ឆ្នាំ 2009 ស្តីពីការបង្កើត **អាជ្ញាធរទន្លេសាប** ។

ជាមួយនឹងបេសកកម្មការងារស្នូលខាងលើ អាជ្ញាធរទន្លេសាប បានរៀបចំបង្កើត អគ្គលេខាធិការដ្ឋានមួយ ដែលបានកំណត់នៅក្នុងអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ 166 អនក្របក ចុះថ្ងៃទី 30 ខែកក្កដា ឆ្នាំ 2009 សម្រាប់ដំណើរការការងារប្រចាំថ្ងៃ និងចាត់ការទូទៅលើការងារសម្របសម្រួល ទំនាក់ទំនង និងសហការរវាងក្រសួងស្ថាប័ន អាជ្ញាធរដែនដី អង្គការជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលនានា សម្រាប់គ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាបប្រកបដោយនិរន្តរភាព ។

យោងលើមាត្រា 2 ជំពូកទី 2 នៃអនុក្រឹត្យ ដែលចែងពីតួនាទី និងភារកិច្ចរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ដូចខាងក្រោម ៖

- ទទួលបន្ទុកដឹកនាំ ចាត់ចែង និងសម្របសម្រួល រាល់សកម្មភាពការងារ ប្រចាំថ្ងៃរបស់អាជ្ញាធរទន្លេសាប
- សិក្សាស្រាវជ្រាវ អំពីសក្តានុពលធនធានធម្មជាតិ ដែលមានក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- សិក្សាស្រាវជ្រាវ ត្រួតពិនិត្យ វាយតម្លៃ និងតាមដាន លើការធ្វើអាជីវកម្ម និងការប្រើប្រាស់ធនធានធម្មជាតិ ដែលមានក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- ប្រមូលទិន្នន័យ និងវិភាគនូវរាល់ព័ត៌មាន និងសកម្មភាពជាក់ស្តែង ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រ ចំពោះមុខ និងយូរអង្វែង ជូនរាជរដ្ឋាភិបាល ក្នុងការកំណត់ទីតាំងគោលដៅបម្រើដល់កិច្ច អភិវឌ្ឍន៍ និងអភិរក្ស
- រៀបចំគោលនយោបាយ ទស្សនវិស័យ បេសកកម្មរបស់អាជ្ញាធរទន្លេសាប
- សម្របសម្រួល និងសហការ ជាមួយបណ្តាក្រសួងស្ថាប័ន អាជ្ញាធរដែនដីពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលនានា លើរាល់សកម្មភាពទាក់ទងនឹងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ក្នុងតំបន់ទន្លេសាបប្រកបដោយនិរន្តរភាព

- សហការ ជាមួយបណ្តាក្រសួងស្ថាប័ន អាជ្ញាធរដែនដីពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា ដើម្បីរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ កម្មវិធីគម្រោងអភិរក្ស អភិវឌ្ឍន៍ផ្សេងៗ ដែលមាននៅក្នុងតំបន់ទន្លេសាប
- រៀបចំចងក្រងឯកសារទិន្នន័យ ព័ត៌មាន ដើម្បីអប់រំផ្សព្វផ្សាយ
- ធ្វើរបាយការណ៍ប្រចាំខែ ឆមាស និងប្រចាំឆ្នាំ ជូនប្រធានអាជ្ញាធរទន្លេសាប
- អនុវត្តន៍ភារកិច្ចផ្សេងៗ ដែលប្រធានអាជ្ញាធរទន្លេសាប ប្រគល់ជូន ។

## ២. រចនាសម្ព័ន្ធ និងការគ្រប់គ្រង

ដោយយោងលើអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ក្នុងមាត្រា 3 ជំពូក 3 ដែលចែងពីរចនាសម្ព័ន្ធ និងការគ្រប់គ្រង គឺមាននាយកដ្ឋានចំនួន 04 អមដោយការិយាល័យចំនួន 14 និងបានកំណត់ពីតួនាទី ភារកិច្ចទទួលខុសត្រូវតាមនាយកដ្ឋាន និងការិយាល័យនីមួយៗដូចមានចែងក្នុងប្រកាសលេខ 025 អទស ចុះថ្ងៃទី 21 ខែ ធ្នូ ឆ្នាំ 2009 ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះបណ្តានាយកដ្ឋាន ក្រោមឱវាទអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ។ នាយកដ្ឋាន និងការិយាល័យស្ថិតក្រោមឱវាទ រួមមាន ៖

- នាយកដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ — ការិយាល័យចំនួន 04
- នាយកដ្ឋានធនធានធម្មជាតិ — ការិយាល័យចំនួន 04
- នាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស — ការិយាល័យចំនួន 03
- នាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ — ការិយាល័យចំនួន 03

ជាក់ស្តែង ការរៀបចំកសាងផែនការសកម្មភាពប្រចាំឆ្នាំ 2016 របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ក្នុងបំណងឆ្លុះបញ្ចាំងឲ្យឃើញពីទិសដៅ និងសកម្មភាពការងារអាទិភាពប្រចាំឆ្នាំ ដើម្បីជម្រុញដល់ការអនុវត្តផែនការយុទ្ធសាស្ត្រអាជ្ញាធរទន្លេសាប (2016-2020) ឲ្យសម្រេចបានជោគជ័យ តាមទិសដៅជាយុទ្ធសាស្ត្រសម្រាប់រយៈពេល 5 ឆ្នាំ និងលើកកម្ពស់ប្រសិទ្ធភាពការងាររបស់អាជ្ញាធរទន្លេសាប ក្នុងបេសកកម្មការងារ **សម្របសម្រួលដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប** ។

# ផ្នែកទី ២

## វឌ្ឍនភាពអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ 2015

### ១. សេចក្តីផ្តើម

ផែនការសកម្មភាពប្រចាំឆ្នាំ 2015 របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ដែលបានរៀបចំឡើង ក្នុងការចូលរួមចំណែកលើកកម្ពស់ការអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល ឈានទៅសម្រេចឲ្យបាននូវគោលដៅអភិវឌ្ឍន៍សហវត្សរ៍កម្ពុជា ។ ផែនការសកម្មភាពនេះ បានកំណត់ពីសកម្មភាពការងារអាទិភាពរបស់នាយកដ្ឋានក្រោមឱវាទអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ដើម្បីអនុវត្តសម្រេចនូវគោលបំណង លទ្ធផល (Outcome) និងធាតុចេញ (Output) ដោយប្រើប្រាស់នូវកញ្ចប់ថវិកាជាតិប្រចាំឆ្នាំ 2015 ។

### ២. វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពឆ្នាំ 2015

### ២.១. លទ្ធផលសម្រេចបានសំខាន់ៗ

បន្ទាប់ពីផែនការសកម្មភាពប្រចាំឆ្នាំអគ្គលេខាធិការដ្ឋាន អាជ្ញាធរទន្លេសាប 2015-2017 ត្រូវបានអនុម័តនាដើមឆ្នាំ 2015 ។ អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប បានរៀបចំធ្វើការផ្សព្វផ្សាយដល់ក្រសួង ស្ថាប័ន និងនាយកដ្ឋានពាក់ព័ន្ធ ដើម្បីរួមសហការ និងអនុវត្តន៍ឲ្យមានប្រសិទ្ធភាព ។

ឆ្លងតាមការតាមដានត្រួតពិនិត្យ និងវាយតម្លៃពីវឌ្ឍនភាពការងារនៃការអនុវត្តរយៈពេល ១ ឆ្នាំ (2015) បានបង្ហាញឲ្យឃើញថា សកម្មភាពការងារ ដែលបានកំណត់ក្នុងផែនការសកម្មភាពប្រចាំឆ្នាំ 2015 សម្រេចបាន 73 (ភាគរយ) និងមានសកម្មភាពការងារចំនួន 27 (ភាគរយ) មិនទាន់បានអនុវត្តន៍ពេញលេញផងដែរ។

❖ **ថ្នាក់អគ្គលេខាធិការដ្ឋាន**

- ✓ ការចុះអនុវត្តការងារអធិការកិច្ច វិនាសកម្មព្រៃលិចទឹកតំបន់ជុំវិញបឹងទន្លេសាប
- ✓ ការចុះតាមដានត្រួតពិនិត្យភាពអនាធិបតេយ្យ និងបទល្មើសក្នុងការធ្វើអាជីវកម្មភាពហួសហេតុ និងខុសច្បាប់មកលើធនធានធម្មជាតិ និងធនធានជលផល
- ✓ សម្របសម្រួលជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីប្រមូលចងក្រងព័ត៌មាន ទិន្នន័យដែលមានស្រាប់អំពីតំបន់ដីសើមនៅតំបន់ជុំវិញបឹងទន្លេសាប
- ✓ ការចុះសិក្សា និងប្រមូលព័ត៌មាន ទិន្នន័យប្រើប្រាស់កាកសំណល់រឹង និងរាវតំបន់ជុំវិញបឹងទន្លេសាប
- ✓ សម្របសម្រួលជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើបច្ចុប្បន្នភាពទិន្នន័យភូមិបណ្តែតទឹក
- ✓ ការចុះសិក្សា និងប្រមូលព័ត៌មាន ទិន្នន័យពីផលិតភាពដំណាំកសិកម្មតំបន់ជុំវិញបឹងទន្លេសាប
- ✓ ការចូលរួមលើកកម្ពស់ការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល
- ✓ ការបន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយក្រសួងស្ថាប័ន និងដៃគូពាក់ព័ន្ធនានា

❖ **ថ្នាក់នាយកដ្ឋាន**

**នាយកដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ**

- ✓ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលក្នុងអាជ្ញាធរទន្លេសាប ត្រូវបានពង្រឹង និងមានដំណើរការល្អប្រសើរ

- ✓ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ត្រូវបានយកចិត្តទុកដាក់ ប្រកបដោយប្រសិទ្ធភាព
- ✓ ប្រព័ន្ធគ្រប់គ្រងបុគ្គលិកមន្ត្រីរាជការ ត្រូវបានលើកកម្ពស់ ប្រកបដោយសមធម៌
- ✓ ការកសាងសមត្ថភាពមន្ត្រីរាជការ ត្រូវបានយកចិត្តទុកដាក់ខ្ពស់ ក្នុងការពង្រឹងការងារ
- ✓ ពង្រឹងការរៀបចំ និងការអនុវត្តផែនការ ប្រកបដោយប្រសិទ្ធភាព
- ✓ យកចិត្តទុកដាក់ដល់ការគ្រប់គ្រងព័ត៌មាន ទិន្នន័យ ក្នុងអាជ្ញាធរទន្លេសាប
- ✓ ចូលរួមលើកកម្ពស់ និងពង្រឹងកិច្ចសហប្រតិបត្តិការទាំងផ្ទៃក្នុង និងខាងក្រៅ

**នាយកដ្ឋានធនធានធម្មជាតិ**

- ✓ ការចុះសិក្សាស្រាវជ្រាវពីប្រភេទព្រៃលិចទឹក និងរុក្ខជាតិជុំវិញបឹងទន្លេសាប
- ✓ ការចុះសិក្សាស្រាវជ្រាវពីសុខុមាលភាពបឹង ស្ទឹងសំខាន់ៗជុំវិញបឹងទន្លេសាប
- ✓ ការចុះសិក្សាស្រាវជ្រាវពីគុណភាពដីកសិកម្ម តាមតំបន់សំខាន់ៗជុំវិញបឹងទន្លេសាប
- ✓ ការចុះសិក្សាស្រាវជ្រាវពីធនធានរ៉ែតាមតំបន់សំខាន់ៗជុំវិញបឹងទន្លេសាប
- ✓ ការចុះសិក្សាស្រាវជ្រាវពីជីវៈចម្រុះជុំវិញបឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ
- ✓ ការចុះសិក្សាបច្ចុប្បន្នភាពទិន្នន័យប្រព័ន្ធស្រោចស្រពស្ទឹងសំខាន់ៗ និងអាងស្រែជុំវិញបឹងទន្លេសាប

**នាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស**

- ✓ ការចុះសិក្សា និងវាយតម្លៃផលចាប់តាមឡូត៍ដាយរាជធានីភ្នំពេញ និងខេត្តកណ្តាល
- ✓ ការចុះសិក្សាសង្វាក់អាជីវកម្មធនធានជលផលតាមច្រករបៀងជុំវិញបឹងទន្លេសាប
- ✓ ការចុះសិក្សាតាមដានពីផលចាប់ធនធានជលផល តាមស្ទឹងសំខាន់ៗជុំវិញបឹងទន្លេសាប
- ✓ ការចុះស្រង់បច្ចុប្បន្នភាពឧបករណ៍នេសាទតាមបណ្តាលខេត្តជុំវិញបឹងទន្លេសាប
- ✓ ការចុះសិក្សារៀបចំបញ្ជីសារពើភ័ណ្ឌតំបន់អភិរក្សជលផល ជុំវិញបឹងទន្លេសាប

**នាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ**

- ✓ ការចុះពង្រឹងការអនុវត្តបទដ្ឋានគតិយុត្តពាក់ព័ន្ធកិច្ចការពារធនធានធម្មជាតិតំបន់បឹងទន្លេសាប
- ✓ ការចុះសិក្សាស្រាវជ្រាវពីលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកិច្ចការពារធនធានធម្មជាតិ និងជីវៈចម្រុះតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ
- ✓ ការចុះសិក្សាស្វែងយល់ពីការបែងចែកអត្ថប្រយោជន៍ រវាងអ្នកពាក់ព័ន្ធ ក្នុងការប្រើប្រាស់ធនធានធម្មជាតិតំបន់បឹងទន្លេសាប ប្រកបដោយនិរន្តរភាព
- ✓ បញ្ជ្រាបការយល់ដឹងជាសាធារណៈអំពីកិច្ចការពារធនធានធម្មជាតិ និងជីវៈចម្រុះបឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ
- ✓ ការធ្វើបច្ចុប្បន្នភាពប្រព័ន្ធផ្សព្វផ្សាយ និងការចែករំលែកព័ត៌មានជាសាធារណៈ

## ២.២ មេរៀន និងបទពិសោធន៍នៃការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ 2015

ឆ្លងតាមការត្រួតពិនិត្យ និងវាយតម្លៃអំពីការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ 2015 របស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរទន្លេសាប បានឆ្លុះបញ្ចាំងឲ្យឃើញពីបញ្ហាធំៗមួយចំនួន ដែលជាបញ្ហាប្រឈមនឹងចំពោះដំណើរ

ការអនុវត្តផែនការសកម្មភាពរបស់នាយកដ្ឋាននីមួយៗ និងមិនអាចសម្រេចបានជោគជ័យទាំងស្រុងបានទៅតាមសកម្មភាពការងារ ដែលបានលើកឡើងក្នុងផែនការសកម្មភាពការងារប្រចាំឆ្នាំ ។

បញ្ហាប្រឈម ទាំងនោះរួមមាន ៖

- ✓ សមត្ថភាពចំណេះដឹង និងបទពិសោធន៍ការងាររបស់មន្ត្រីរដ្ឋបាល និងបច្ចេកទេស នៅមានកម្រិត ទាំងការទទួលខុសត្រូវ និងការអនុវត្តការងារ
- ✓ សម្ភារៈបច្ចេកទេស ចុះអនុវត្តន៍ការងារ នៅមានការខ្វះខាត
- ✓ ការផ្តល់កិច្ចសហប្រតិបត្តិការ អាជ្ញាធរដែនដី និងមន្ត្រីក្រសួងស្ថាប័នពាក់ព័ន្ធ នៅមានកម្រិត ដោយសារការបាត់បង់ផលប្រយោជន៍ពីឈ្មួញ
- ✓ សកម្មភាពការងារ ដែលបានលើកឡើងមានចំនួនច្រើន ដែលប៉ះពាល់ដល់ទំហំថវិកា ពេលវេលា និងសមត្ថភាពមនុស្ស មិនអាចសម្រេចបានជោគជ័យគ្រប់សកម្មភាពទាំងស្រុង

# ផ្នែកទី ៣

# គម្រោងសកម្មភាពការងារអាទិភាពសំខាន់ៗ

# ផែនការយុទ្ធសាស្ត្រអាជ្ញាធរទន្លេសាប (2016-2020)

## ១. លក្ខណៈទូទៅ

ផែនការយុទ្ធសាស្ត្រអាជ្ញាធរទន្លេសាប ២០១៦-២០២០ ត្រូវបានអនុម័តដោយប្រធាន អាជ្ញាធរទន្លេសាប ដើម្បីដាក់ឲ្យអនុវត្តន៍រយៈពេល ៥ ឆ្នាំ គឺជាផែនការយុទ្ធសាស្ត្រដំណាក់កាលដំបូង សម្រាប់ធ្វើជាឧបករណ៍បង្ហាញទិស ដែលបានឆ្លុះបញ្ចាំងពីក្របខ័ណ្ឌកម្មវិធីអាទិភាព សូចនាករ ក្របខ័ណ្ឌពេលវេលាច្បាស់លាស់ និងយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃផ្អែកលើក្របខ័ណ្ឌលទ្ធផល តាមរយៈការអនុវត្តផែនការសកម្មភាពអាទិភាព ដើម្បីសម្រេចឲ្យបានតាមទិសដៅជាយុទ្ធសាស្ត្រ ។ ម្យ៉ាងទៀតផែនការយុទ្ធសាស្ត្រនេះ ក៏ជាផែនទីបង្ហាញទិសដល់ក្រសួងស្ថាប័នទាំងកម្រិតថ្នាក់ជាតិ និងកម្រិតថ្នាក់ក្រោមជាតិពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា ដែលមានគោលបំណងសហការ និងគាំទ្រទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដល់អាជ្ញាធរទន្លេសាប ។ ជាពិសេសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីធ្វើការពិនិត្យពិចារណាវិភាជន៍កញ្ចប់ថវិកាគាំទ្រប្រចាំឆ្នាំ ដល់អាជ្ញាធរទន្លេសាប ក្នុងការអនុវត្តសកម្មភាពកាងារអាទិភាពរបស់ផែនការយុទ្ធសាស្ត្ររយៈពេល ៥ ឆ្នាំ និងផែនការសកម្មភាពប្រចាំឆ្នាំ ប្រកបដោយភាពជោគជ័យ ។

សកម្មភាពការងារអាទិភាពសំខាន់ៗ របស់ផែនការយុទ្ធសាស្ត្រអាជ្ញាធរទន្លេសាប 2016-2020 គឺជាសកម្មភាពគាំទ្រដល់ការអនុវត្តផែនការយុទ្ធសាស្ត្ររយៈពេល 5 ឆ្នាំ សំដៅសម្រេចឲ្យបានជោគជ័យ ប្រកបដោយប្រសិទ្ធភាពតាមទិសដៅការងារនីមួយៗ ( តារាងម៉ាទ្រីសទី 1 ) ។

## ២. គម្រោងសកម្មភាពការងារអាទិភាពសំខាន់ៗ

ផែនការយុទ្ធសាស្ត្រអាជ្ញាធរទន្លេសាប បានកំណត់ទិសដៅការងារជាយុទ្ធសាស្ត្រចំនួន 05 ដើម្បីអនុវត្តន៍ចាប់ពីឆ្នាំ 2016 ដល់ឆ្នាំ 2020 ។ ដោយឡែក នៅក្នុងទិសដៅការងារជាយុទ្ធសាស្ត្រនីមួយៗ ក៏បានកំណត់ពីគម្រោងសកម្មភាពការងារអាទិភាពសំខាន់ៗច្រើន ដែលនឹងត្រូវអនុវត្តន៍ក្នុងអំឡុងពេល 5 ឆ្នាំ ។

**ទិសដៅការងារទី ១.** ពង្រឹងគោលនយោបាយ បទបញ្ញត្តិ និងស្ថាប័ន

**គម្រោងសកម្មភាព** ១.១. លើកកម្ពស់គោលនយោបាយគ្រប់គ្រងធនធានទឹកឲ្យបានទូលំទូលាយនៅប្រទេសកម្ពុជារួមទាំងនៅថ្នាក់តំបន់ និងនៅតំបន់ជុំវិញទន្លេសាប

១.១.១. ពង្រឹងនិងពង្រីកការយល់ដឹងពីគោលនយោបាយគ្រប់គ្រងធនធានទឹកទាំងនៅថ្នាក់តំបន់ ថ្នាក់ជាតិ និងតំបន់ជុំវិញទន្លេសាប

**គម្រោងសកម្មភាព** ១.២. សម្របសម្រួលបញ្ជ្រាបផែនការយុទ្ធសាស្ត្រគ្រប់គ្រងតំបន់ទន្លេសាប ក្នុងគោលនយោបាយយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

១.២.១. បង្កើតសូចនាករ/សកម្មភាពអាទិភាព នៃផែនការយុទ្ធសាស្ត្រគ្រប់គ្រងតំបន់ទន្លេសាប

១.២.២. សម្របសម្រួលជាមួយក្រសួងផែនការ និងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចកម្ពុជា ដើម្បីពិនិត្យ និងដាក់បញ្ចូលក្នុងបច្ចុប្បន្នភាពគោលនយោបាយយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

**គម្រោងសកម្មភាព** ១.៣. សម្របសម្រួលជាមួយក្រសួងស្ថាប័ន និងភាគីពាក់ព័ន្ធ ដើម្បីដាក់បញ្ចូលគោលការណ៍ការគ្រប់គ្រងធនធានទឹកចម្រុះក្នុងបទបញ្ញត្តិ/ផែនការតាមវិស័យ និងជម្រុញឲ្យមានសុខដុមនីយកម្មតាមការចាំបាច់

**គម្រោងសកម្មភាព** ២.១. សម្របសម្រួល និងប្រតិបត្តិតាម រាល់បទបញ្ញត្តិពាក់ព័ន្ធនឹងច្បាប់ធនធានទឹក និងក្របខ័ណ្ឌការងារនៃការគ្រប់គ្រងអាងទន្លេរបស់ព្រះរាជាណាចក្រកម្ពុជា

២.១.១. ពង្រឹង និងពង្រីកការយល់ដឹងបន្ថែមអំពីបទបញ្ញត្តិពាក់ព័ន្ធនឹងច្បាប់ធនធានទឹក

២.១.២. ពង្រឹង និងពង្រីកការយល់ដឹងពីក្របខ័ណ្ឌការងារនៃការគ្រប់គ្រងអាងទន្លេ

**គម្រោងសកម្មភាព** ២.២. កំណត់ដែនវិសាលភាពនៃតំបន់ទន្លេសាប (ព្រះរាជក្រឹត្យ មាត្រា ២)

២.២.១. ប្រមូលចងក្រងនូវព័ត៌មាន ទិន្នន័យពាក់ព័ន្ធនឹងវិសាលភាពនៃតំបន់ទន្លេសាប

២.២.២. រៀបចំសេចក្តីព្រាងអនុក្រឹត្យកំណត់ដែនវិសាលភាពនៃតំបន់ទន្លេសាប

២.២.៣. អនុក្រឹត្យកំណត់ដែនវិសាលភាពនៃតំបន់ទន្លេសាប ត្រូវបានអនុម័ត

**គម្រោងសកម្មភាព** ៣.១. ចាត់ចែងរៀបចំដំណើរការការងារឲ្យបានទៀងទាត់ (ប្រជុំ សិក្ខាសាលា...) ស្របតាមលក្ខន្តិកៈការងារពាក់ព័ន្ធភារកិច្ចរបស់អាជ្ញាធរទន្លេសាប

**គម្រោងសកម្មភាព** ៣.២. សម្របសម្រួល និងសហការជិតស្និតជាមួយក្រសួងស្ថាប័នជំនាញពាក់ព័ន្ធ ក្នុងការបង្កើនប្រសិទ្ធភាពការអនុវត្តច្បាប់ បទដ្ឋានគតិយុត្តពាក់ព័ន្ធការលើកកម្ពស់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ធនធានធម្មជាតិ និងប្រព័ន្ធអេកូឡូស៊ីតំបន់បឹងទន្លេសាប

៣.២.១. ពង្រឹង និងពង្រីកការយល់ដឹងបន្ថែមអំពីបទបញ្ញត្តិពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានជលផល

៣.២.២. ពង្រឹង និងពង្រីកការយល់ដឹងបន្ថែមអំពីបទបញ្ញត្តិពាក់ព័ន្ធនឹង ការគ្រប់គ្រងធនធានធម្មជាតិ និង បរិស្ថាន

**គម្រោងសកម្មភាព** ៣.៣. បន្តស្មារតីចូលរួមអនុវត្តន៍បទដ្ឋានគតិយុត្ត ក្នុងកិច្ចការការពារដែនព្រៃលិចទឹកជុំវិញតំបន់ទន្លេសាប (តំបន់ ៣)

៣.៣.១. ចុះអធិការកិច្ចដែនព្រៃលិចទឹក និងថែទាំបង្គោលតំបន់ ៣ តាមស្មារតីអនុក្រឹត្យលេខ 197 អនក្រ

៣.៣.២. សហការ និងការពារ ថែរក្សា និងដាំព្រៃលិចទឹក

**ទិសដៅការងារទី ២.** ពង្រឹងការយល់ដឹងជាមូលដ្ឋានអំពីការគ្រប់គ្រងទន្លេសាប

**គម្រោងសកម្មភាព** ៤.១. សិក្សាស្រាវជ្រាវពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន និងធនធានធម្មជាតិតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ

៤.១.១. សិក្សាចងក្រង និងធ្វើបច្ចុប្បន្នភាពស្ថិតិប្រជាសាស្ត្រ ជុំវិញតំបន់ទន្លេសាប

៤.១.២. សិក្សាចងក្រងព័ត៌មាន ទិន្នន័យពាក់ព័ន្ធធនធានបរិស្ថានវិទ្យា (Ecology Resources) តំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ

៤.១.៣. សិក្សាចងក្រងព័ត៌មាន ទិន្នន័យពាក់ព័ន្ធនឹងផលប៉ះពាល់បរិស្ថាន (Environment) តំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ

៤.១.៤. សិក្សាចងក្រងព័ត៌មានទិន្នន័យពាក់ព័ន្ធនឹងផលប៉ះពាល់សង្គមសេដ្ឋកិច្ច (Social-economic) តំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ

**គម្រោងសកម្មភាព** ៤.២. រៀបចំបញ្ជីសារពើភ័ណ្ឌប្រភពធនធានទឹក ស្ថិតក្នុងក្របខ័ណ្ឌផែនការគ្រប់គ្រងអាងទន្លេនៅក្នុងតំបន់ទន្លេសាប

៤.២.១. សិក្សាចងក្រងព័ត៌មាន ទិន្នន័យប្រភពធនធានទឹកនៅជុំវិញតំបន់ទន្លេសាប

៤.២.២. ចងក្រងបញ្ជីសារពើភ័ណ្ឌប្រភពធនធានទឹកនៅជុំវិញតំបន់ទន្លេសាប

**គម្រោងសកម្មភាព** ៤.៣. រៀបចំបញ្ជីសារពើភ័ណ្ឌតំបន់ដីសើមជុំវិញតំបន់ទន្លេសាប

៤.៣.១. សិក្សាចងក្រងព័ត៌មាន ទិន្នន័យតំបន់ដីសើមនៅជុំវិញតំបន់ទន្លេសាប

**គម្រោងសកម្មភាព** ៥.១. គាំទ្រ និងសហការជាមួយក្រសួងស្ថាប័នជាតិក្នុងការពង្រឹង/បង្កើតឲ្យមានបណ្តាញទំនាក់ទំនងការងារតាមដានត្រួតពិនិត្យ អំពីផលប៉ះពាល់ ទៅលើធនធានធម្មជាតិ បរិស្ថាន និងលក្ខខណ្ឌសេដ្ឋកិច្ច សង្គមកិច្ច

៥.១.១. សម្របសម្រួលជាមួយក្រសួងស្ថាប័នជាតិ ក្នុងការរៀបចំបង្កើតឲ្យមានបណ្តាញទំនាក់ទំនងការងារ ក្នុងការចែករំលែកព័ត៌មាន ទិន្នន័យ

**គម្រោងសកម្មភាព** ៥.២. គាំទ្រ និងសហការជាមួយក្រសួងស្ថាប័នជាតិ ក្នុងការពង្រឹងនីតិវិធី/វិធីសាស្ត្រតាមដានត្រួតពិនិត្យ និងវាយតម្លៃអំពីផលប៉ះពាល់មកលើធនធានធម្មជាតិ បរិស្ថាន និងលក្ខខណ្ឌសេដ្ឋកិច្ច សង្គមកិច្ច

៥.២.១. សម្របសម្រួលជាមួយក្រសួងស្ថាប័នជាតិ ក្នុងការរៀបចំបង្កើត និងពង្រឹងនីតិវិធី/វិធីសាស្ត្រតាមដានត្រួតពិនិត្យ និងវាយតម្លៃ

៥.២.២. ចូលរួមសហការជាមួយក្រសួង-ស្ថាប័នជាតិ ក្នុងការចែករំលែកព័ត៌មាន ទិន្នន័យពីផលប៉ះពាល់ធនធានធម្មជាតិ បរិស្ថាន និងលក្ខខណ្ឌសេដ្ឋកិច្ច សង្គមកិច្ច

**គម្រោងសកម្មភាព** ៥.៣. បង្កើតវេទិកា (Platform) ចែករំលែក និងការផ្សព្វផ្សាយព័ត៌មានទិន្នន័យពាក់ព័ន្ធសក្តានុពលនៃតំបន់ទន្លេសាប

៥.៣.១. ពង្រឹងប្រសិទ្ធភាពការងាររបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ក្នុងការសិក្សាស្រាវជ្រាវព័ត៌មាន ទិន្នន័យនៅតំបន់ទន្លេសាប

៥.៣.២. ជម្រុញប្រសិទ្ធភាពការងារផ្សព្វផ្សាយព័ត៌មាន ទិន្នន័យ ក្នុងគេហទំព័រនិងការបោះពុម្ព

៥.៣.៣. រៀបចំសន្និសីទ (Symposium) ប្រចាំឆ្នាំ សម្រាប់អ្នកពាក់ព័ន្ធ

**ទិសដៅការងារទី ៣.** សម្របសម្រួល កសាងផែនការ និងគ្រប់គ្រង

**គម្រោងសកម្មភាព** ៦.១. សម្របសម្រួល និងគាំទ្រវាល់កិច្ចដំណើរការអភិវឌ្ឍប្រកបដោយចិរភាពក្នុងកិច្ចការការពារធនធានធម្មជាតិ និងបរិស្ថានតំបន់ជុំវិញបឹងទន្លេសាប

៦.១.១. ចូលរួមផ្លាស់ប្តូរបទពិសោធន៍ និងចែករំលែកការយល់ដឹង ក្នុងកិច្ចដំណើរការអភិវឌ្ឍប្រកបដោយចិរភាព ក្នុងកិច្ចការការពារធនធានធម្មជាតិ និងបរិស្ថាន

**គម្រោងសកម្មភាព** ៦.២. សម្របសម្រួលបណ្តាញការងារជាមួយថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិលើបទបញ្ញត្តិនៃការគ្រប់គ្រងធនធានទឹក និងការគ្រប់គ្រងអាងទន្លេ

៦.២.១. សិក្សាចងក្រងរាល់ឯកសារបច្ចេកទេស និងបទបញ្ញត្តិពាក់ព័ន្ធនឹងដំណើរការការងារនៃការគ្រប់គ្រងធនធានទឹក និងការគ្រប់គ្រងអាងទន្លេ

**គម្រោងសកម្មភាព** ៧.១. បង្កើតនូវយន្តការបច្ចេកទេស អំពីនីតិវិធីនៃការតាមដានត្រួតពិនិត្យ និងពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ អំពីនីតិវិធីអនុវត្តន៍គម្រោងនីមួយៗនៅតំបន់ទន្លេសាប

៧.១.១. សិក្សាចងក្រងប្រព័ន្ធព័ត៌មាន ទិន្នន័យគម្រោងដែលបាននឹងកំពុងអនុវត្តន៍ក្នុងតំបន់ទន្លេសាប

៧.១.២. សម្របសម្រួលរៀបចំយន្តការ និងនីតិវិធីតាមដានត្រួតពិនិត្យ និងវាយតម្លៃគម្រោងនីមួយៗ ដែលបាននឹងកំពុងអនុវត្តន៍នៅតំបន់ទន្លេសាប

៧.១.៣. សម្របសម្រួល និងសហកាចុះវាយតម្លៃគម្រោងនីមួយៗ ដែលបាននឹងកំពុងអនុវត្តន៍នៅតំបន់ទន្លេសាប

**គម្រោងសកម្មភាព** ៧.២. ពង្រឹងការយល់ដឹង អំពីវិធីសាស្ត្រ និងនីតិវិធីនៃការតាមដានត្រួតពិនិត្យ និងវាយតម្លៃរបស់កម្មវិធី/គម្រោង

៧.២.១. បង្កើតកម្មវិធីពង្រឹងសមត្ថភាពមន្ត្រីបច្ចេកទេស អំពីវិធីសាស្ត្រ និងនីតិវិធីនៃការតាមដានត្រួតពិនិត្យ និងវាយតម្លៃកម្មវិធី/គម្រោង

**គម្រោងសកម្មភាព** ៨.១. របាយការណ៍/សេចក្តីអត្ថាធិប្បាយបច្ចេកទេសអំពីស្ថានភាពតំបន់ទន្លេសាបរួមមានសេដ្ឋកិច្ចសង្គម បរិស្ថាន និងធនធានធម្មជាតិ ( State of Tonle Sap Lake )

៨.១.១. របាយការណ៍/សេចក្តីអត្ថាធិប្បាយបច្ចេកទេសអំពីស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ចតំបន់ទន្លេសាប

៨.១.២. របាយការណ៍/សេចក្តីអត្ថាធិប្បាយបច្ចេកទេសអំពីធនធានធម្មជាតិ បរិស្ថានតំបន់ទន្លេសាប

**គម្រោងសកម្មភាព** ៨.២. កសាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តំបន់ទន្លេសាប

៨.២.១. រៀបចំយន្តការការងារ និងវិធីសាស្ត្រ ដើម្បីរៀបចំផែនការអភិវឌ្ឍន៍តំបន់ទន្លេសាប

៨.២.២. វិភាគកំណត់បញ្ហា និងស្ថានភាពតំបន់ទន្លេសាប

៨.២.៣. រៀបចំសេចក្តីព្រាងផែនការអភិវឌ្ឍន៍តំបន់ទន្លេសាប

៨.២.៤. ផែនការអភិវឌ្ឍន៍តំបន់ទន្លេសាប ត្រូវបានអនុម័ត

**ទិសដៅការងារទី ៤.** ការទំនាក់ទំនង និងការកសាងសមត្ថភាពភាគីពាក់ព័ន្ធ

**គម្រោងសកម្មភាព** ៩.១. រៀបចំកសាង និងអនុវត្តន៍ផែនការទំនាក់ទំនង យកចិត្តទុកដាក់ទាំងព័ត៌មានបច្ចេកទេស និងឧបករណ៍បង្កើនការយល់ដឹងឲ្យបានទូលំទូលាយ ដូចជា ៖ ឯក

សារផ្នែករឹង និងទុន ការកំណត់ដៃគូ និងបណ្តាញការងារ សម្រាប់ពង្រីកការផ្សព្វផ្សាយ

៩.១.១. រៀបចំកសាងផែនការប្រាស្រ័យទំនាក់ទំនង/សម្របសម្រួល Communication Plan

៩.១.២. ពង្រឹងយន្តការអនុវត្ត និងផ្សព្វផ្សាយផែនការទំនាក់ទំនង/សម្របសម្រួល

**គម្រោងសកម្មភាព** ១០.១. ពង្រឹងការអនុវត្តផែនការនៃការចូលរួមអ្នកពាក់ព័ន្ធ និងលើកកម្ពស់ការកសាងសមត្ថភាព

១០.១.១. បង្កើនការលើកទឹកចិត្ត ដល់ការចូលរួមរបស់អ្នកពាក់ព័ន្ធ

១០.១.២. ពង្រឹងការយល់ដឹងដល់មន្ត្រីអាជ្ញាធរទន្លេសាប និងអ្នកពាក់ព័ន្ធ

**គម្រោងសកម្មភាព** ១០.២. បង្កើនប្រសិទ្ធភាពការងារភាពជាដៃគូតាមរយៈបណ្តាញការងារជាមួយអ្នកពាក់ព័ន្ធ (ក្រុមអ្នកប្រើប្រាស់, អង្គការមិនមែនរដ្ឋាភិបាល, កសិករ, សហគមន៍.....)

១០.២.១. រៀបចំកម្មវិធីទស្សនកិច្ចសិក្សា ដើម្បីផ្លាស់ប្តូរចំណេះដឹង និងចែករំលែកបទពិសោធន៍

**ទិសដៅការងារទី ៥.** ការប្រតិបត្តិរបស់អាជ្ញាធរទន្លេសាប ប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព

**គម្រោងសកម្មភាព** ១១.១. តាមដានត្រួតពិនិត្យ វាយតម្លៃរាល់ក្របខ័ណ្ឌ និងសកម្មភាពការងារ ដែលអនុវត្តន៍ជាប្រចាំ រួមជាមួយនឹងត្រួតពិនិត្យឡើងវិញនៅពាក់កណ្តាលអាណត្តិឆ្នាំ ២០១៩

១១.១.១.តាមដានត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តប្រចាំឆ្នាំ

១១.១.២.វាយតម្លៃវឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រ

**គម្រោងសកម្មភាព** ១១.២. ដឹកនាំ និងពង្រឹងនូវការអនុវត្តផែនការយុទ្ធសាស្ត្រ

១១.២.១. រៀបចំ និងបោះពុម្ពផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រអាជ្ញាធរទន្លេសាប ២០១៦-២០២០

១១.២.២. រៀបចំ និងបោះពុម្ពផ្សព្វផ្សាយផែនការប្រតិបត្តិប្រចាំឆ្នាំ

១១.២.៣. ស្វែងរក និងកៀរគរការគាំទ្រទាំងផ្នែកថវិកា និងបច្ចេកទេស សម្រាប់អនុវត្តន៍គម្រោងសកម្មភាព របស់អាជ្ញាធរទន្លេសាប

**គម្រោងសកម្មភាព** ១២.១. ពង្រឹង និងពង្រីកបណ្តាញទំនាក់ទំនងការងារ ជាមួយក្រុមប្រឹក្សាយោបល់នៃម្ចាស់ជំនួយ (Donor Consultative Group) គាំទ្រទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ

១២.១.១. ផ្សាភ្ជាប់រវាងអង្គការចាត់តាំងរបស់អាជ្ញាធរទន្លេសាបជាមួយនឹងដៃគូអភិវឌ្ឍន៍ម្ចាស់ ជំនួយ

**គម្រោងសកម្មភាព** ១២.២ សម្របសម្រួលក្នុងតួនាទីបណ្តាញការងារអង្គការអាងទន្លេ

**គម្រោងសកម្មភាព** ១២.៣. សមាហរណកម្មប្រភពថវិកា/មូលនិធិខាងក្នុងរបស់អាជ្ញាធរទន្លេសាប(ថវិការដ្ឋ, ម្ចាស់ជំនួយ, គម្រោងនានា...)

១២.៣.១.ពង្រឹងប្រសិទ្ធភាពការងារក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ

១២.៣.២. កសាងផែនការកម្មវិធីថវិកាប្រចាំឆ្នាំ របស់អាជ្ញាធរទន្លេសាប

**គម្រោងសកម្មភាព** ១៣.១. ជួសជុលថែទាំ គ្រឿងសង្ហារឹម និងប្រេងឥន្ទនៈសម្រាប់អាជ្ញាធរទន្លេសាប

១៣.១.១.ជួសជុលថែទាំ និងការផ្គត់ផ្គង់សេវាផ្សេងៗ សម្រាប់អគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប

១៣.១.២.ផ្គត់ផ្គង់សម្ភារៈបរិក្ខា គ្រឿងសង្ហារឹម សម្រាប់អគារអាជ្ញាធរទន្លេសាប

១៣.១.៣.ផ្គត់ផ្គង់ប្រេងឥន្ធនៈ សម្រាប់ដំណើរការការងារអាជ្ញាធរទន្លេសាប

**គម្រោងសកម្មភាព** ១៣.២.នីតិវិធី បទបញ្ញត្តិផ្ទៃក្នុង សម្រាប់ដំណើរការការងារប្រចាំ

១៣.២.១.ពង្រឹងប្រសិទ្ធភាពការងារក្នុងការគ្រប់គ្រងរដ្ឋបាល

១៣.២.២.ពង្រឹងប្រសិទ្ធភាពការងារក្នុងការគ្រប់គ្រងបុគ្គលិក-មន្ត្រីរាជការ

**គម្រោងសកម្មភាព** ១៣.៣.ជ្រើសរើសមន្ត្រីប្រកបដោយសមត្ថភាព តាមការចាំបាច់

១៣.៣.១ សម្របសម្រួលនិងប្រឹក្សាជាមួយក្រសួងធនធានទឹកនិងឧតុនិយមនិងក្រសួងមុខងារសាធារណៈ

១៣.៣.២.ផ្សព្វផ្សាយជាសាធារណៈ ប្រឡងជ្រើសរើសមន្ត្រីជំនាញ តាមតម្រូវការចាំបាច់

**គម្រោងសកម្មភាព** ១៣.៤.កសាងសមត្ថភាពមន្ត្រីអាជ្ញាធរទន្លេសាប និងក្រសួងស្ថាប័នពាក់ព័ន្ធ

១៣.៤.១. កសាងសមត្ថភាពជំនាញផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ

១៣.៤.២. កសាងសមត្ថភាពពង្រឹងផ្នែករៀបចំកសាងផែនការ

១៣.៤.៣. កសាងសមត្ថភាពជំនាញផ្នែកស្រាវជ្រាវ និងច្បាប់

## ៣. តារាងម៉ាទ្រីសផែនការសកម្មភាពការងារ (២០១៦-២០២០)

| លទ្ធផលរំពឹងទុក | សកម្មភាព/គម្រោង | រយៈពេលកំណត់នៃការអនុវត្ត | | | | | ថវិកាគាំទ្រ (លានរៀល) |
|---|---|---|---|---|---|---|---|
| | | 2016 | 2017 | 2018 | 2019 | 2020 | |
| **ទិសដៅការងារទី ១. ពង្រឹងគោលនយោបាយ បទបញ្ញត្តិ និងស្ថាប័ន** | | | | | | | 5,930 |
| ១. គោលនយោបាយសម្រាប់ការណែនាំអភិបាលកិច្ចទឹក និងសកម្មភាពការងារអាជ្ញាធរទន្លេសាប | ១.១.លើកកម្ពស់គោលនយោបាយគ្រប់គ្រងធនធានទឹកឲ្យបានទូលំទូលាយនៅប្រទេសកម្ពុជារួមទាំងនៅថ្នាក់តំបន់ និងនៅតំបន់ជុំវិញទន្លេសាប | √ | √ | √ | √ | √ | 275 |
| | ១.១.១.ពង្រឹង និងពង្រីកការយល់ដឹងពីគោលនយោបាយគ្រប់គ្រងធនធានទឹកទាំងនៅថ្នាក់តំបន់ ថ្នាក់ជាតិ និងតំបន់ជុំវិញទន្លេសាប | √ | √ | √ | √ | √ | 275 |
| | ១.២.សម្របសម្រួលបញ្ជ្រាបផែនការយុទ្ធសាស្ត្រគ្រប់គ្រងតំបន់ទន្លេសាប ក្នុងគោលនយោបាយយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ | | | √ | √ | √ | 85 |
| | ១.២.១.បង្កើតសូចនាករ/សកម្មភាពអាទិភាពនៃផែនការយុទ្ធសាស្ត្រគ្រប់គ្រងតំបន់ទន្លេសាប | | | √ | √ | √ | 50 |
| | ១.២.២.សម្របសម្រួលជាមួយក្រសួងផែនការ និងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចកម្ពុជា ដើម្បីពិនិត្យ និងដាក់បញ្ចូលក្នុងបច្ចុប្បន្នភាពគោលនយោបាយយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ | | | √ | √ | √ | 35 |
| | ១.៣.សម្របសម្រួល និងប្រឹក្សាជាមួយក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធ ដើម្បីលើកកម្ពស់គោលការណ៍គ្រប់គ្រងធនធានទឹកចម្រុះក្នុងបទបញ្ញត្តិ/ផែនការតាមវិស័យ និងជម្រុញឲ្យមានសុខដុមនីយកម្មតាមការចាំបាច់ | √ | √ | √ | √ | √ | 60 |
| ២. បទបញ្ញត្តិអភិបាលកិច្ចទឹក ត្រូវបានបង្កើតឡើងនៅតំបន់ទន្លេសាប | ២.១.សម្របសម្រួល និងប្រតិបត្តិតាម រាល់បទបញ្ញត្តិពាក់ព័ន្ធច្បាប់ធនធានទឹក និងក្របខ័ណ្ឌការងារគ្រប់គ្រងអាងទន្លេរបស់ព្រះរាជាណាចក្រកម្ពុជា | √ | √ | √ | √ | √ | 360 |
| | ២.១.១.ពង្រឹង និងពង្រីកការយល់ដឹងបន្ថែមអំពីបទបញ្ញត្តិពាក់ព័ន្ធនឹងច្បាប់ធនធានទឹក | √ | √ | √ | √ | √ | 180 |
| | ២.១.២.ពង្រឹង និងពង្រីកការយល់ដឹងពីក្របខ័ណ្ឌការងារគ្រប់គ្រងអាងទន្លេ | √ | √ | √ | √ | √ | 180 |
| | ២.២.កំណត់ដែនវិសាលភាពតំបន់ទន្លេសាប (ព្រះរាជក្រឹត្យមាត្រា ២) | √ | √ | √ | √ | √ | 885 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ២.២.១.ប្រមូលចងក្រងនូវព័ត៌មាន ទិន្នន័យពាក់ព័ន្ធវិសាលភាពតំបន់ទន្លេសាប | √ | √ | √ | √ | √ | 460 |
| | ២.២.២.រៀបចំសេចក្ដីព្រាងអនុក្រឹត្យកំណត់ដែនវិសាលភាពនៃតំបន់ទន្លេសាប | | | | √ | √ | 270 |
| | ២.២.៣.អនុក្រឹត្យកំណត់ដែនវិសាលភាពនៃតំបន់ទន្លេសាបត្រូវបានអនុម័ត | | | | √ | √ | 155 |
| ៣. រាល់ធាតុសំខាន់ៗនៃច្បាប់ បទដ្ឋានគតិយុត្ត និងតួនាទីភារកិច្ចទទួលខុសត្រូវរបស់អាជ្ញាធរទន្លេសាបត្រូវបានប្រតិបត្តិ និងបង្កើនប្រសិទ្ធភាពការងារ | ៣.១.ចាត់ចែងរៀបចំដំណើរការការងារឲ្យបានទៀងទាត់ (ប្រជុំ សិក្ខាសាលា ...) ស្របតាមលក្ខន្តិកៈការងារពាក់ព័ន្ធភារកិច្ចរបស់អាជ្ញាធរទន្លេសាប | √ | √ | √ | √ | √ | 375 |
| | ៣.២.សម្របសម្រួល និងសហការជិតស្និតជាមួយក្រសួងស្ថាប័នជំនាញពាក់ព័ន្ធក្នុងការបង្កើនប្រសិទ្ធភាពការអនុវត្តច្បាប់ បទដ្ឋានគតិយុត្តពាក់ព័ន្ធការលើកកម្ពស់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ធនធានធម្មជាតិ និងប្រព័ន្ធអេកូឡូស៊ីតំបន់បឹងទន្លេសាប | √ | √ | √ | √ | √ | 390 |
| | ៣.២.១.ពង្រឹង និងពង្រីកការយល់ដឹងបន្ថែមអំពីបទបញ្ញត្តិពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានជលផល | √ | √ | √ | √ | √ | 195 |
| | ៣.២.២.ពង្រឹង និងពង្រីកការយល់ដឹងបន្ថែមអំពីបទបញ្ញត្តិពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន | √ | √ | √ | √ | √ | 195 |
| | ៣.៣.បន្តស្មារតីចូលរួមអនុវត្តន៍បទដ្ឋានគតិយុត្ត ក្នុងកិច្ចការការពារដែនព្រៃលិចទឹកជុំវិញតំបន់ទន្លេសាប (តំបន់ ៣) | √ | √ | √ | √ | √ | 3,500 |
| | ៣.៣.១.ចុះអធិការកិច្ចដែនព្រៃលិចទឹក និងថៃទាំបង្គោលទឹកតំបន់ ៣ ស្របតាមស្មារតីអនុក្រឹត្យលេខ 197 អនក្រ | √ | √ | √ | √ | √ | 2,000 |
| | ៣.៣.២.សហការ និងការពារ ថែរក្សា និងដាំព្រៃលិចទឹក | √ | √ | √ | √ | √ | 1,500 |
| **ទិសដៅការងារទី ២. ពង្រឹងការយល់ដឹងជាមូលដ្ឋានអំពីការគ្រប់គ្រងទន្លេសាប** | | | | | | | 6,620 |
| ៤. មូលដ្ឋានទិន្នន័យសេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន និងធនធានធម្មជាតិតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ | ៤.១.សិក្សាស្រាវជ្រាវពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន និងធនធានធម្មជាតិតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ | √ | √ | √ | √ | √ | 3,650 |
| | ៤.១.១.សិក្សាចងក្រង និងធ្វើបច្ចុប្បន្នភាពស្ថិតិប្រជាសាស្ត្រ ជុំវិញតំបន់ទន្លេសាប | √ | √ | √ | √ | √ | 400 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ត្រូវបានពង្រឹងក្នុងការប្រមូលចងក្រង និងផ្សព្វផ្សាយ | ៤.១.២.សិក្សាចងក្រងព័ត៌មាន ទិន្នន័យពាក់ព័ន្ធធនធានបិរស្ថានវិទ្យា (Ecology Resources) តំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ | √ | √ | √ | √ | √ | 1,500 |
| | ៤.១.៣.សិក្សាចងក្រងព័ត៌មាន ទិន្នន័យពាក់ព័ន្ធនឹងផលប៉ះពាល់បរិស្ថាន (Environment) តំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ | √ | √ | √ | √ | √ | 1,000 |
| | ៤.១.៤.សិក្សាចងក្រងព័ត៌មាន ទិន្នន័យពាក់ព័ន្ធនឹងផលប៉ះពាល់សង្គមសេដ្ឋកិច្ច (Social-economic) តំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ | √ | √ | √ | √ | √ | 750 |
| | ៤.២.រៀបចំបញ្ជីសារពើភ័ណ្ឌប្រភពធនធានទឹក ស្ថិតក្នុងក្របខ័ណ្ឌផែនការគ្រប់គ្រងអាងទន្លេនៅក្នុងតំបន់ទន្លេសាប | √ | √ | √ | | | 525 |
| | ៤.២.១.សិក្សាចងក្រងព័ត៌មាន ទិន្នន័យប្រភពធនធានទឹកនៅជុំវិញតំបន់ទន្លេសាប | √ | √ | √ | | | 425 |
| | ៤.២.២.ចងក្រងបញ្ជីសារពើភ័ណ្ឌប្រភពធនធានទឹកនៅជុំវិញតំបន់ទន្លេសាប | √ | √ | √ | | | 100 |
| | ៤.៣.រៀបចំបញ្ជីសារពើភ័ណ្ឌតំបន់ដីសើមជុំវិញតំបន់ទន្លេសាប | √ | √ | √ | | | 500 |
| | ៤.៣.១.សិក្សាចងក្រងព័ត៌មាន ទិន្នន័យតំបន់ដីសើមនៅជុំវិញតំបន់ទន្លេសាប | √ | √ | √ | | | 400 |
| | ៤.៣.២.ចងក្រងបញ្ជីសារពើភ័ណ្ឌតំបន់ដីសើមនៅជុំវិញតំបន់ទន្លេសាប | | | √ | | | 100 |
| ៥. ការគ្រប់គ្រង និងយន្តការចែករំលែកព័ត៌មាន ទិន្នន័យ | ៥.១.គាំទ្រ និងសហការជាមួយក្រសួងស្ថាប័នជាតិក្នុងការពង្រឹង/បង្កើតឲ្យមានបណ្តាញទំនាក់ទំនងការងារតាមដានត្រួតពិនិត្យ អំពីផលប៉ះពាល់ទៅលើធនធានធម្មជាតិ បរិស្ថាន និងលក្ខខណ្ឌសេដ្ឋកិច្ចសង្គមកិច្ច | √ | √ | √ | √ | √ | 75 |
| | ៥.១.១.សម្របសម្រួលជាមួយក្រសួងស្ថាប័នជាតិ ក្នុងការរៀបចំបង្កើត ឲ្យមានបណ្តាញទំនាក់ទំនងការងារ ក្នុងការចែករំលែកព័ត៌មាន ទិន្នន័យ | √ | √ | √ | √ | √ | 75 |
| | ៥.២.គាំទ្រ និងសហការជាមួយក្រសួងស្ថាប័នជាតិ ក្នុងការពង្រឹងនីតិវិធី/វិធីសាស្រ្តតាមដានត្រួតពិនិត្យ និងវាយតម្លៃអំពីផលប៉ះពាល់មកលើធនធានធម្មជាតិ បរិស្ថាន និងលក្ខខណ្ឌសេដ្ឋកិច្ច សង្គមកិច្ច | √ | √ | √ | √ | √ | 235 |
| | ៥.២.១.សម្របសម្រួលជាមួយក្រសួងស្ថាប័នជាតិ រៀបចំបង្កើត និងពង្រឹងនីតិវិធី/វិធីសាស្រ្តតាមដានត្រួតពិនិត្យ និងវាយតម្លៃ | √ | √ | √ | √ | √ | 125 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ៥.២.២.ចូលរួមសហការជាមួយក្រសួងស្ថាប័នជាតិ ក្នុងការចែករំលែកព័ត៌មាន ទិន្នន័យពីផលប៉ះពាល់ធនធានធម្មជាតិ បរិស្ថាននិងលក្ខណសេដ្ឋកិច្ច សង្គមកិច្ច | √ | √ | √ | √ | √ | 110 |
| | ៥.៣.បង្កើតវេទិកា (Platform) ចែករំលែក និងផ្សព្វផ្សាយព័ត៌មានទិន្នន័យពាក់ព័ន្ធសក្តានុពលនៃតំបន់ទន្លេសាប | √ | √ | √ | √ | √ | 1,635 |
| | ៥.៣.១.ពង្រឹងប្រសិទ្ធភាពការងាររបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរទន្លេសាប ក្នុងការសិក្សាស្រាវជ្រាវព័ត៌មាន ទិន្នន័យនៅតំបន់ទន្លេសាប | | √ | √ | √ | √ | 170 |
| | ៥.៣.២.ជម្រុញប្រសិទ្ធភាពការងារផ្សព្វផ្សាយព័ត៌មាន ទិន្នន័យ ក្នុងគេហទំព័រ និងការបោះពុម្ព | | √ | √ | √ | √ | 215 |
| | ៥.៣.៣.រៀបចំសន្និសីទ (Symposium) ប្រចាំឆ្នាំ សម្រាប់អ្នកពាក់ព័ន្ធ | | √ | √ | √ | √ | 1,250 |
| **ទិសដៅការងារទី ៣. សម្របសម្រួល កសាងផែនការ និងគ្រប់គ្រង** | | | | | | | 3,270 |
| ៦. ការគ្រប់គ្រងប្រកបដោយចិរភាព ស្របតាមបទបញ្ញត្តិពាក់ព័ន្ធនឹងក្របខ័ណ្ឌការងារគ្រប់គ្រងអាងទន្លេ | ៦.១.សម្របសម្រួល និងគាំទ្រពលកិច្ចដំណើរការអភិវឌ្ឍប្រកបដោយចិរភាព ក្នុងកិច្ចការការពារធនធានធម្មជាតិ និងបរិស្ថានតំបន់ជុំវិញបឹងទន្លេសាប | √ | √ | √ | √ | √ | 200 |
| | ៦.១.១.ចូលរួមផ្លាស់ប្តូរបទពិសោធន៍ និងចែករំលែកការយល់ដឹង ក្នុងកិច្ចដំណើរការអភិវឌ្ឍ ប្រកបដោយចិរភាព ក្នុងកិច្ចការការពារធនធានធម្មជាតិ និងបរិស្ថាន | √ | √ | √ | √ | √ | 200 |
| | ៦.២.សម្របសម្រួលបណ្តាញការងារជាមួយថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិលើបទបញ្ញត្តិនៃការគ្រប់គ្រងធនធានទឹក និងការគ្រប់គ្រងអាងទន្លេ | √ | √ | √ | √ | √ | 110 |
| | ៦.២.១.សិក្សាចងក្រងរាល់ឯកសារបច្ចេកទេស និងបទបញ្ញត្តិពាក់ព័ន្ធនឹងដំណើរការការងារនៃការគ្រប់គ្រងធនធានទឹក និងការគ្រប់គ្រងអាងទន្លេ | √ | √ | √ | √ | √ | 110 |
| ៧. ការយល់ដឹង និងសម្របសម្រួលបណ្តាគម្រោងក្នុងតំបន់ទន្លេសាប | ៧.១.បង្កើតនូវយន្តការបច្ចេកទេស អំពីនីតិវិធីនៃការតាមដានត្រួតពិនិត្យ និងពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ អំពីនីតិវិធីអនុវត្តន៍គម្រោងនីមួយៗនៅតំបន់ទន្លេសាប | √ | √ | √ | √ | √ | 635 |
| | ៧.១.១.សិក្សាចងក្រងប្រព័ន្ធព័ត៌មាន ទិន្នន័យគម្រោង ដែលបាននឹងកំពុងអនុវត្តន៍ក្នុងតំបន់ទន្លេសាប | √ | √ | √ | √ | √ | 225 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ៧.១.២.សម្របសម្រួលជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីសិក្សាស្វែងយល់ពីនីតិវិធី/វិធីសាស្ត្រតាមដានត្រួតពិនិត្យ និងវាយតម្លៃរបស់គម្រោងនីមួយៗ ដែលបាននឹងកំពុងអនុវត្តន៍នៅតំបន់ទន្លេសាប | √ | √ | √ | √ | √ | 185 |
| | ៧.១.៣.សម្របសម្រួល និងសហការ ដើម្បីចូលរួមវាយតម្លៃពីការអនុវត្តគម្រោងនីមួយៗនៅតំបន់ទន្លេសាប | √ | √ | √ | √ | √ | 225 |
| | ៧.២.ពង្រឹងការយល់ដឹង អំពីវិធីសាស្ត្រ និងនីតិវិធីនៃការតាមដានត្រួតពិនិត្យ និងវាយតម្លៃរបស់កម្មវិធី/គម្រោង | √ | √ | √ | √ | √ | 175 |
| | ៧.២.១.បង្កើតកម្មវិធីពង្រឹងសមត្ថភាពមន្ត្រីបច្ចេកទេស អំពីវិធីសាស្ត្រ និងនីតិវិធីនៃការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃកម្មវិធី/គម្រោង | √ | √ | √ | √ | √ | 175 |
| ៨. ក្របខ័ណ្ឌនៃផែនការគ្រប់គ្រងតំបន់ទន្លេសាប ត្រូវបានរៀបចំ និងផ្សព្វផ្សាយ | ៨.១.របាយការណ៍/សេចក្តីអត្ថាធិប្បាយបច្ចេកទេសអំពីស្ថានភាពតំបន់ទន្លេសាប រួមមានសេដ្ឋកិច្ចសង្គម បរិស្ថាន និងធនធានធម្មជាតិ ( State of Tonle Sap Lake ) | √ | √ | √ | √ | √ | 1,200 |
| | ៨.១.១.របាយការណ៍/សេចក្តីអត្ថាធិប្បាយបច្ចេកទេសអំពីស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ចតំបន់ទន្លេសាប | √ | √ | √ | √ | √ | 600 |
| | ៨.១.២.របាយការណ៍/សេចក្តីអត្ថាធិប្បាយបច្ចេកទេសអំពីធនធានធម្មជាតិបរិស្ថានតំបន់ទន្លេសាប | √ | √ | √ | √ | √ | 600 |
| | ៨.២.កសាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តំបន់ទន្លេសាប | | | √ | √ | √ | 950 |
| | ៨.២.១.រៀបចំយន្តការការងារ និងវិធីសាស្ត្រ ដើម្បីរៀបចំផែនការអភិវឌ្ឍន៍តំបន់ទន្លេសាប | | | √ | √ | √ | 220 |
| | ៨.២.២.វិភាគកំណត់បញ្ហា និងស្ថានភាពតំបន់ទន្លេសាប | | | √ | √ | √ | 310 |
| | ៨.២.៣.រៀបចំសេចក្តីព្រាងផែនការអភិវឌ្ឍន៍តំបន់ទន្លេសាប | | | | √ | √ | 240 |
| | ៨.២.៤.ផែនការអភិវឌ្ឍន៍តំបន់ទន្លេសាប ត្រូវបានអនុម័ត | | | | | √ | 180 |
| **ទិសដៅការងារទី ៤. ការទំនាក់ទំនង និងការកសាងសមត្ថភាពភាគីពាក់ព័ន្ធ** | | | | | | | 1,595 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៩. មុខងារសំខាន់របស់បឹងទន្លេសាប ត្រូវបានយល់ដឹងជាសាធារណៈ តាមរយៈការទំនាក់ទំនង និងការផ្សព្វផ្សាយព័ត៌មាន | ៩.១.រៀបចំកសាង និងអនុវត្តន៍ផែនការទំនាក់ទំនង ដែលយកចិត្តទុកដាក់ទាំងព័ត៌មានបច្ចេកទេស និងឧបករណ៍ក្នុងការបង្កើនការយល់ដឹងឲ្យបានទូលំទូលាយ ដូចជា ៖ ឯកសារផ្នែករឹង និងទុន ការកំណត់ដៃគូ និងបណ្តាញការងារ សម្រាប់ពង្រីកការផ្សព្វផ្សាយ | √ | √ | √ | | | 405 |
| | ៩.១.១.រៀបចំកសាងផែនការប្រាស្រ័យទំនាក់ទំនង/សម្របសម្រួល Communication Plan | √ | √ | √ | | | 275 |
| | ៩.១.២.ផ្សព្វផ្សាយ និងអនុវត្តន៍ផែនការទំនាក់ទំនង/សម្របសម្រួល | √ | √ | √ | | | 130 |
| ១០. សមត្ថភាពភាគីពាក់ព័ន្ធក្នុងការចែករំលែក និងសហការក្នុងការអភិវឌ្ឍន៍ការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន ជីវៈចម្រុះ ប្រព័ន្ធអេកូឡូស៊ី និងលក្ខខណ្ឌសេដ្ឋកិច្ចសង្គមកិច្ចនៃតំបន់បឹងទន្លេសាប | ១០.១.ពង្រឹងការអនុវត្តផែនការនៃការចូលរួមរបស់អ្នកពាក់ព័ន្ធ និងលើកកម្ពស់ការកសាងសមត្ថភាព | √ | √ | √ | √ | √ | 475 |
| | ១០.១.១.បង្កើនការលើកទឹកចិត្ត ដល់ការចូលរួមរបស់អ្នកពាក់ព័ន្ធ | √ | √ | √ | √ | √ | 75 |
| | ១០.១.២.ពង្រឹងការយល់ដឹងដល់មន្ត្រីអាជ្ញាធរទន្លេសាប និងអ្នកពាក់ព័ន្ធ | √ | √ | √ | √ | √ | 400 |
| | ១០.២.បង្កើនប្រសិទ្ធភាពការងារក្នុងភាពជាដៃគូតាមរយៈបណ្តាញការងារជាមួយអ្នកពាក់ព័ន្ធ (ក្រុមអ្នកប្រើប្រាស់, អង្គការមិនមែនរដ្ឋាភិបាល, កសិករ, សហគមន៍.....) | √ | √ | √ | √ | √ | 715 |
| | ១០.២.១.រៀបចំកម្មវិធីទស្សនកិច្ចសិក្សា ដើម្បីផ្លាស់ប្តូរចំណេះដឹង និងចែករំលែកបទពិសោធន៍ | √ | √ | √ | √ | √ | 715 |
| **ទិសដៅការងារទី ៥. ការប្រតិបត្តិរបស់អាជ្ញាធរទន្លេសាប ប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព** | | | | | | | 9,610 |
| ១១. ប្រសិទ្ធភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រ | ១១.១.តាមដានត្រួតពិនិត្យ និងវាយតម្លៃរាល់ក្របខ័ណ្ឌ និងរាល់សកម្មភាពការងារ ដែលអនុវត្តន៍ជាប្រចាំ រួមជាមួយនឹងត្រួតពិនិត្យឡើងវិញ នៅពាក់កណ្តាលអាណត្តិឆ្នាំ ២០១៩ | √ | √ | √ | √ | √ | 295 |
| | ១១.១.១.តាមដានត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តប្រចាំឆ្នាំ | √ | √ | √ | √ | √ | 125 |
| | ១១.១.២.វាយតម្លៃវឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រ | | | | √ | √ | 170 |
| | ១១.២.ដឹកនាំ និងពង្រឹងនូវការអនុវត្តផែនការយុទ្ធសាស្ត្រ | √ | √ | √ | √ | √ | 585 |
| | ១១.២.១.រៀបចំ និងបោះពុម្ពផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រ របស់អាជ្ញាធរ | √ | | | | | 150 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ទន្លេសាប ២០១៦-២០២០ | | | | | | |
| | ១១.២.២.រៀបចំ និងបោះពុម្ពផ្សព្វផ្សាយផែនការប្រតិបត្តិប្រចាំឆ្នាំ | √ | √ | √ | √ | √ | 400 |
| | ១១.២.៣.ស្វែងរក និងកៀរគរការគាំទ្រទាំងផ្នែកថវិកា និងបច្ចេកទេស សម្រាប់ អនុវត្តន៍គម្រោងសកម្មភាពរបស់អាជ្ញាធរទន្លេសាប | √ | √ | √ | √ | √ | 35 |
| ១២. ធនធានហិរញ្ញវត្ថុ និងដៃគូគាំទ្រដល់បេសកកម្មការងាររបស់អាជ្ញាធរទន្លេសាប | ១២.១.ពង្រឹង និងពង្រីកបណ្តាញទំនាក់ទំនងការងារជាមួយក្រុមប្រឹក្សាយោបល់នៃម្ចាស់ជំនួយ ( Donor Consultative Group ) ក្នុងការគាំទ្រទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ | √ | √ | √ | √ | √ | 25 |
| | ១២.១.១.ផ្សាភ្ជាប់រវាងអង្គការចាត់តាំងរបស់អាជ្ញាធរទន្លេសាបជាមួយនឹងដៃគូអភិវឌ្ឍន៍ និងម្ចាស់ជំនួយ | √ | √ | √ | √ | √ | 25 |
| | ១២.២.សម្របសម្រួលក្នុងតួនាទីបណ្តាញការងារអង្គការអាងទន្លេ | √ | √ | √ | √ | √ | 100 |
| | ១២.២.១.បង្កើតឲ្យមានបណ្តាញទំនាក់ទំនងការងារជាមួយនឹងអង្គការអាងទន្លេ | | | | | | 100 |
| | ១២.៣.សមាហរណកម្មប្រភពថវិកា/មូលនិធិខាងក្នុងរបស់អាជ្ញាធរទន្លេសាប (ថវិការដ្ឋ, ម្ចាស់ជំនួយ, គម្រោងនានា... ) | √ | √ | √ | √ | √ | 250 |
| | ១២.៣.១.ពង្រឹងប្រសិទ្ធភាពការងារក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ | √ | √ | √ | √ | √ | 125 |
| | ១២.៣.២.កសាងផែនការកម្មវិធីថវិកាប្រចាំឆ្នាំ របស់អាជ្ញាធរទន្លេសាប | √ | √ | √ | √ | √ | 125 |
| ១៣. ធនធានមនុស្ស និងសម្ភារៈ គ្រឿងបរិក្ខារ និងនីតិវិធី រដ្ឋបាល ដើម្បីគាំទ្រដល់ការអនុវត្ត សកម្មភាពរបស់អាជ្ញាធរទន្លេសាប | ១៣.១.ជួសជុលថែទាំ គ្រឿងសង្ហារឹម និងប្រេងឥន្ទនៈសម្រាប់អាជ្ញាធរទន្លេសាប | √ | √ | √ | √ | √ | 7,000 |
| | ១៣.១.១.ជួសជុលថែទាំ និងការផ្គត់ផ្គង់សេវាផ្សេងៗ សម្រាប់អគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប | √ | √ | √ | √ | √ | 500 |
| | ១៣.១.២.ផ្គត់ផ្គង់សម្ភារៈបរិក្ខារ គ្រឿងសង្ហារឹម សម្រាប់អគារអាជ្ញាធរទន្លេសាប | √ | √ | √ | √ | √ | 1500 |
| | ១៣.១.៣.ផ្គត់ផ្គង់ប្រេងឥន្ទនៈ សម្រាប់ដំណើរការការងារអាជ្ញាធរទន្លេសាប | √ | √ | √ | √ | √ | 5,000 |
| | ១៣.២.នីតិវិធី បទបញ្ញត្តិផ្ទៃក្នុង សម្រាប់ដំណើរការការងារប្រចាំ | √ | √ | √ | √ | √ | 250 |
| | ១៣.២.១.ពង្រឹងប្រសិទ្ធភាពការងារក្នុងការគ្រប់គ្រងរដ្ឋបាល | √ | √ | √ | √ | √ | 125 |
| | ១៣.២.២.ពង្រឹងប្រសិទ្ធភាពការងារក្នុងការគ្រប់គ្រងបុគ្គលិក-មន្ត្រីរាជការ | √ | √ | √ | √ | √ | 125 |
| | ១៣.៣.ជ្រើសរើសមន្ត្រីប្រកបដោយសមត្ថភាព តាមការចាំបាច់ | √ | | √ | | √ | 105 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ១៣.៣.១ សម្របសម្រួល និងប្រឹក្សាជាមួយក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងមុខងារសាធារណៈ | √ | | √ | | √ | 15 |
| | ១៣.៣.២.ផ្សព្វផ្សាយជាសាធារណៈ ប្រឡងជ្រើសរើសមន្ត្រីជំនាញតាមតម្រូវការចាំបាច់ | √ | | √ | | √ | 90 |
| | ១៣.៤.កសាងសមត្ថភាពមន្ត្រីអាជ្ញាធរទន្លេសាប និងក្រសួងស្ថាប័នពាក់ព័ន្ធ | √ | √ | √ | √ | √ | 1,000 |
| | ១៣.៤.១.កសាងសមត្ថភាពជំនាញផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ | √ | √ | √ | √ | √ | 250 |
| | ១៣.៤.២.កសាងសមត្ថភាពពង្រឹងផ្នែករៀបចំកសាងផែនការ | √ | √ | √ | √ | √ | 250 |
| | ១៣.៤.៣.កសាងសមត្ថភាពជំនាញផ្នែកស្រាវជ្រាវ និងច្បាប់ | √ | √ | √ | √ | √ | 500 |

# ផ្នែកទី ៤

## ផែនការសកម្មភាពប្រចាំឆ្នាំ 2016 របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប

### ១. លក្ខណៈទូទៅ

ផែនការសកម្មភាពប្រចាំឆ្នាំ 2016 របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប គឺជាសកម្មភាពការងារលម្អិតក្នុងការប្រតិបត្តិការងារ រួមជាមួយនឹងការចូលរួមសហការពីបណ្ដាក្រសួងស្ថាប័នទាំងកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សង្គមស៊ីវិល អង្គការជាតិ-អន្តជាតិ និងដៃគូអភិវឌ្ឍន៍នានា ដើម្បីជម្រុញប្រសិទ្ធភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រអាជ្ញាធរទន្លេសាបរយៈពេល 5 ឆ្នាំ (2016-2020) ឲ្យទទួលបានជោគជ័យ ។

ជាក់ស្តែង ផែនការសកម្មភាពនេះ ត្រូវបានរៀបចំឡើងដោយបន្សីជាមួយគម្រោងសកម្មភាពការងារអាទិភាពសំខាន់ៗ (ដូចក្នុងតារាង 1) នៃផែនការយុទ្ធសាស្ត្រអាជ្ញាធរទន្លេសាប ។ ជាពិសេសស្របទៅតាមតួនាទីភារកិច្ចការងារ ដែលបានកំណត់ក្នុងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរទន្លេសាប ដើម្បីពង្រឹងប្រសិទ្ធភាពការងារ និងគាំទ្រដល់បេសកកម្មការងាររបស់អាជ្ញាធរទន្លេសាបក្នុងការសម្របសម្រួល ដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបនទន្លេសាប ប្រកបដោយនិរន្តភាព ។

### ២. សកម្មភាពការងារប្រចាំឆ្នាំ 2016 របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប

**ទិសដៅការងារទី ១.** ពង្រឹងគោលនយោបាយ បទបញ្ញត្តិ និងស្ថាប័ន

**គម្រោងសកម្មភាព** ១.១. លើកកម្ពស់គោលនយោបាយគ្រប់គ្រងធនធានទឹកឲ្យបានទូលំទូលាយនៅប្រទេសកម្ពុជារួមទាំងនៅថ្នាក់តំបន់ និងនៅតំបន់ជុំវិញទន្លេសាប

១.១.១. ពង្រឹងនិងពង្រីកការយល់ដឹងពីគោលនយោបាយគ្រប់គ្រងធនធានទឹកទាំងនៅថ្នាក់តំបន់ថ្នាក់ជាតិ និងតំបន់ជុំវិញទន្លេសាប

- សម្របសម្រួលប្រឹក្សាជាមួយក្រសួង ស្ថាប័នជំនាញពាក់ព័ន្ធ ក្នុងការចែករំលែកព័ត៌មាន អំពីគោលនយោបាយគ្រប់គ្រងធនធានទឹកទាំងនៅកម្រិតថ្នាក់ជាតិ ថ្នាក់តំបន់
- ផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងពីគោលនយោបាយគ្រប់គ្រងធនធានទឹកថ្នាក់ជាតិ និងថ្នាក់តំបន់ដល់មន្ត្រីអាជ្ញាធរទន្លេសាប
- បន្សីកម្មវិធីការងារអាទិភាពអាជ្ញាធរទន្លេសាបជាមួយគោលនយោបាយអភិវឌ្ឍន៍ធនធានទឹករបស់រាជរដ្ឋាភិបាល (ក្រសួងធនធានទឹក និងឧតុនិយម)

**គម្រោងសកម្មភាព** ១.៣. សម្របសម្រួល និងប្រឹក្សាជាមួយក្រសួងស្ថាប័ន និងភាគីពាក់ព័ន្ធ ដើម្បីលើកកម្ពស់គោលការណ៍គ្រប់គ្រងធនធានទឹកចម្រុះក្នុងបទបញ្ញត្តិ/ផែនការតាមវិស័យ និងជម្រុញ ឲ្យមានសុខដុមនីយកម្មតាមការចាំបាច់

**គម្រោងសកម្មភាព** ២.១. សម្របសម្រួល និងប្រតិបត្តិតាម រាល់បទបញ្ញត្តិពាក់ព័ន្ធនឹងច្បាប់ធនធានទឹក និងក្របខ័ណ្ឌការងារនៃការគ្រប់គ្រងអាងទន្លេរបស់ព្រះរាជាណាចក្រកម្ពុជា

២.១.១. ពង្រឹង និងពង្រីកការយល់ដឹងបន្ថែមអំពីបទបញ្ញាតិពាក់ព័ន្ធនឹងច្បាប់ធនធានទឹក

- សម្របសម្រួលប្រឹក្សាជាមួយក្រសួងធនធានទឹក និងឧតុនិយម ក្នុងការចែករំលែកព័ត៌មាន និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងច្បាប់ធនធានទឹក
- ផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងពីបទបញ្ញត្តិ និងច្បាប់ធនធានទឹក នៃព្រះរាជាណាចក្រកម្ពុជា ដល់មន្ត្រីអាជ្ញាធរទន្លេសាប

២.១.២. ពង្រឹង និងពង្រីកការយល់ដឹងពីក្របខ័ណ្ឌការងារនៃការគ្រប់គ្រងអាងទន្លេ

- សម្របសម្រួលប្រឹក្សាជាមួយក្រសួងធនធានទឹក និងឧតុនិយម ក្នុងការចែករំលែកព័ត៌មានបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងក្របខ័ណ្ឌការគ្រប់គ្រងអាងទន្លេ
- ផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងពីបទបញ្ញត្តិ និងក្របខ័ណ្ឌការគ្រប់គ្រងអាងទន្លេ ដល់មន្ត្រីអាជ្ញាធរទន្លេសាប

**គម្រោងសកម្មភាព** ២.២. កំណត់ដែនវិសាលភាពនៃតំបន់ទន្លេសាប (ព្រះរាជក្រឹត្យ មាត្រា ២)

២.២.១. ប្រមូលចងក្រងនូវព័ត៌មាន ទិន្នន័យពាក់ព័ន្ធនឹងវិសាលភាពនៃតំបន់ទន្លេសាប

- សម្របសម្រួលប្រឹក្សាជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ (ក្រសួងធនធានទឹក និងឧតុនិយម, គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា, ក្រសួងបរិស្ថាន .......) ដើម្បីប្រមូល និងចងក្រងរាល់ព័ត៌មានទិន្នន័យ
- សម្របសម្រួលប្រឹក្សាជាមួយអាជ្ញាធរដែនដីពាក់ព័ន្ធជុំវិញទន្លេសាប ដើម្បីប្រមូល និងចងក្រងរាល់ព័ត៌មាន ទិន្នន័យ
- ផ្ទៀងផ្ទាត់ និងស្រង់ព័ត៌មាន ទិន្នន័យតាមបណ្ដាខេត្តពាក់ព័ន្ធជុំវិញតំបន់ទន្លេសាប
- រៀបចំចងក្រងព័ត៌មាន ទិន្នន័យគោល សម្រាប់រៀបចំសេចក្ដីព្រាងអនុក្រឹត្យកំណត់ដែនវិសាលភាពនៃតំបន់ទន្លេសាប

